សប្តាហ៍ទី 37

នំប៉ុងប្រាំដុំ និងត្រីពីរកន្ទុយ

ព្រះយេស៊ូបានបំពេញដង្វាយដ៏តូចតាចរបស់យើង ហើយបានធ្វើការអស្ចារ្យយ៉ាងធំ!
ព្រះអង្គក៏អាចធ្វើបែបនេះនៅក្នុងជីវិតរបស់យើងបានដូចគ្នា។

រឿងក្នុងព្រះគម្ពីរ

មានមនុស្សជាច្រើនបានមកជួបព្រះយេស៊ូ។
ព្រះយេស៊ូស្រឡាញ់ពួកគេ ហើយបានបង្រៀនពួកគេ។
ថ្ងៃកាន់តែជ្រេ ហើយមនុស្សទាំងអស់បានឃ្លាន។
ពួកសិស្សមានតែនំប៉ុងប្រាំដុំ និងត្រីពីរកន្ទុយ ដូច្នេះពួកគេព្រួយបារម្ភ។
ព្រះយេស៊ូបានយកនំប៉ុងប្រាំដុំ និងត្រីពីរកន្ទុយ ហើយអធិស្ឋាននិងអរព្រះគុណ។ បន្ទាប់មកទ្រង់កាច់នំប៉ុង និងត្រី ហើយប្រទានដល់ពួកសិស្ស។ ពេលពួកសិស្សផ្តល់អាហារទៅបណ្តាជន ពួកគេបានបរិភោគ ហើយបានឆ្អែតគ្រប់គ្នា។
ព្រមទាំងនៅសល់ដប់ពីរល្អី!

«ព្រះយេស៊ូយកនំប៉ុងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ព្រះអង្គងើបព្រះភ័ក្ត្រឡើង សរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់នំប៉ុងប្រទានឲ្យពួកសិស្ស ដើម្បីឲ្យគេចែកបណ្តាជនបរិភោគ ព្រះអង្គក៏ចែកត្រីពីរកន្ទុយនោះឲ្យគេទាំងអស់គ្នាដែរ។ អ្នកទាំងនោះបរិភោគឆ្អែតគ្រប់ៗគ្នា។»
(ម៉ាកុស 6:41~42)

នៅពេលដែលយើងថ្វាយអ្វីៗដែលយើងមាន ព្រះយេស៊ូនឹងប្រទានពរយ៉ាងបរិបូរ!



សមិទ្ធផលសម្រេច

វត្ថុបំណង

- រៀនបានថាព្រះយេស៊ូអាចប្តូរពីតង្វាយដ៏តូចទៅជាព្រះពរដ៏អស្ចារ្យ
- ទទួលបទពិសោធនៃការចែករំលែក និងធ្វើសកម្មភាពតាមរយៈការលេង
- ចេះអរព្រះគុណរួមគ្នាជាមួយមិត្តភក្តិ
- រៀនលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ដោយដួងចិត្តអរព្រះគុណ។

សម្ភារៈ



របៀបធ្វើ

1. ដាក់ម្សៅមី និងអំបិលក្នុងចានគោមរួចច្រល់។
2. ពុតម្សៅនោះ សូនជារូបនំប៉ុងចំនួន ៥ និងត្រីចំនួន ២។
3. យកដុំម្សៅដែលបានសូនជារូបរាងរួច ដាក់តម្រៀបនៅលើចានក្រដាស។
4. យកជក់ជ្រលក់ថ្នាំពណ៌ទឹក លាបពីលើរូបនំប៉ុង និងត្រី។
5. គុបតែងលម្អនៅតាមគែមចានក្រដាឱ្យបានស្អាត។
6. រួចរាល់! ព្រះយេស៊ូប្រទានពររបស់តិចតួចក្លាយជាមានបរិបូរណ៌!



ការពង្រីកសកម្មភាព

- សាកល្បងចែករំលែកត្រី និងនំប៉ុងជាមួយមិត្តភក្តិ។
- សួរកុមារថា៖«តើនឹងមានអ្វីកើតឡើងប្រសិនបើមានពេលនោះមានតែនំប៉ុងប្រាំដុំ និងត្រីពីរកន្ទុយ?»
- ដើរតួសម្តែងនូវកិច្ចការដែលព្រះយេស៊ូបានធ្វើជាមួយនំប៉ុង និងត្រី។
- ប្រៀបធៀបចំហំខុសៗគ្នានៃនំប៉ុង និងត្រីដែលកុមារបានធ្វើ។

Tip សម្រាប់គ្រូ

- ទុកពេលវេលាឱ្យបានគ្រប់គ្រាន់ ឱ្យកុមារអាចស្ទាប និងទទួលអារម្មណ៍ពីការច្របាច់ម្សៅ។
- សូមឱ្យកុមារសូនរូបនំប៉ុង និងត្រី តាមការស្រមៃស្រមៃរបស់ពួកគេ។
- ប្រសិនបើទុកឱ្យដុំម្សៅស្ងួតសិន ហើយលាបពណ៌ នោះវានឹងចេញពណ៌មកកាន់តែស្អាត។
- ក្រោយពេលធ្វើហើយ សូមរម្លឹករឿងព្រះគម្ពីរម្តងទៀត និងនិយាយប្រាប់កុមារពីគ្តីអំណាននៃការចែករំលែក។